ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សភាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ ៣០៦

ចុះថ្ងៃទី ២៩_០៣_២០១៣

សាលដីកាព្រហ្មទណ្ឌ

លេខ : ៦៨ "ក្រ.III ណ"

ចុះថ្ងៃទី ០១_១០_២០១៣

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំងនិងសកម្មភាពរបស់សាលាជំរះក្តី ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ ០៦ក្រ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ បានបើកសវនាការជាសាធារណៈនៅសាលសវនាការសាលាឧទ្ធរណ៍ នាថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ២០១៣ ដោយមានសមាសភាពដូចខាងក្រោម:

**<u>ក្រុមប្រឹក្សាជំនុំជម្រះ</u>**

- លោក [redacted] ជាប្រធាន
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោកស្រី [redacted] ជាចៅក្រមប្រឹក្សា

**<u>តំណាងមហាអយ្យការ</u>**

លោក [redacted]

**<u>ក្រឡាបញ្ជីសវនាការ</u>**

លោក [redacted]

**ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ ៣០៦ ចុះថ្ងៃទី ២៩ ខែមីនា ឆ្នាំ២០១៣ ដែលមាន:**

**១- ជនជាប់ចោទឈ្មោះ** [redacted] វ័ត្ន ហៅ [redacted] ថាច ហៅ ខ្ទឹង ភេទប្រុស អាយុ ២០ឆ្នាំ ជាតិខ្មែរ មុខរបរកម្មករផ្លូវ ទីលំនៅសព្វថ្ងៃ [redacted] ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (ស) នៅលីវ ចាប់ខ្លួនថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ២០១១ ឃុំខ្លួនថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ២០១១ (**ដើមបណ្តឹងឧទ្ធរណ៍**)។

**២- ជនជាប់ចោទឈ្មោះ** [redacted] មុន្នីរ័ត្ន ហៅ ក្រាញ់ ភេទប្រុស អាយុ ១៨ឆ្នាំ ជាតិខ្មែរ មុខរបរ ប៉ះកង់ឡាន កើតនៅ [redacted] ទីលំនៅសព្វថ្ងៃផ្ទះលេខ [redacted] ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (រ) នៅលីវ។

**<u>ជាប់ចោទពីបទ:</u>** លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិ ១០ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។



៣២៦

៣- ជនជាប់ចោទឈ្មោះ [redacted] ចាយ ហៅ ចៃ ភេទប្រុស អាយុ ៣៨ឆ្នាំ ជាតិខ្មែរ មុខរបរទិញអេត ចាយ ទីលំនៅសព្វថ្ងៃផ្ទះ [redacted] ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (ស) ប្រពន្ធឈ្មោះ [redacted] ចាប់ខ្លួនថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ២០១១ ឃុំខ្លួនថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ២០១១ ទោសពីមុនធ្លាប់ជាប់ពន្ធនាគារ ១ឆ្នាំ (**ដើមបណ្តឹងឧទ្ធរណ៍**) ។

មានលោក [redacted] ចន្ថា ជាមេធាវីការពារជនជាប់ចោទទាំងពីរនាក់ ។

<u>**ជាប់ចោទពីបទ:**</u> **សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅភូមិ ១០ សង្កាត់បឹង សាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

- **ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ** [redacted] ហៅ ណែត ភេទប្រុស អាយុ ២១ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃផ្ទះលេខ [redacted]

## <u>ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ</u>

កាលពីថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០១១ វេលាម៉ោង ១០ និង០៥នាទី នៅចំណុចមុខផ្ទះលេខ ១៧ ផ្លូវលេខ ២៤៧ ក្រុម ២៨ ភូមិ ១០ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ ឈ្មោះ [redacted] សម្បត្តិ ភេទប្រុស អាយុ ២១ឆ្នាំ បានជិះម៉ូតូម៉ាកហ៊ុយស៊ុយគី ស្មេច ពណ៌ក្រហមខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ ១-៦៦៦៧ ឌុបឈ្មោះ [redacted] សុភាព ភេទប្រុស អាយុ ២៤ឆ្នាំ ទៅតារាងបាល់ ដែលស្ថិតនៅក្នុងចំណុចខាងលើ ដោយឈ្មោះ [redacted] ថាច ហៅ ខ្ទឹង និងបក្សពួកម្នាក់ទៀតបានយកកាំបិតទៅគម្រាមប្លន់យកម៉ូតូ បន្ទាប់ពីប្លន់ ម៉ូតូរួចហើយ ឈ្មោះ [redacted] ថាច បានយកម៉ូតូនោះទៅឱ្យឈ្មោះ [redacted] ចាយ ហៅ ចៃ ដែលជាបក្សពួកយកទៅ លក់ លុះដល់ថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ២០១១ ទើបសមត្ថកិច្ចធ្វើការឃាត់ខ្លួនបានខណៈពេលឈ្មោះ [redacted] ថាច ហៅ ខ្ទឹង ឈ្មោះ [redacted] មុន្នីរ័ត្ន ហៅ ក្រាញ់ និងឈ្មោះ [redacted] ចាយ ហៅ ចៃ កំពុងប្រើប្រាស់គ្រឿងញៀន ។

**បានឃើញ** សាលក្រមព្រហ្មទណ្ឌលេខ ១៣៦ ក្រ.១ "ង" ចុះថ្ងៃទី ២១ ខែធ្នូ ឆ្នាំ២០១១ របស់ **សាលាដំបូងរាជធានីភ្នំពេញ** ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ:

១- ផ្តន្ទាទោសលើ:

ក- ឈ្មោះ [redacted] រ័ត្ន ហៅ [redacted] ថាច ហៅ ខ្ទឹង ភេទប្រុស អាយុ ២០ឆ្នាំ ដាក់ពន្ធនាគារកំណត់ ០៣ (បី) ឆ្នាំ ពីបទ **លួចមានស្ថានទម្ងន់ទោស** ។

ខ- ឈ្មោះ [redacted] មុន្នីរ័ត្ន ហៅ ក្រាញ់ ភេទប្រុស អាយុ ១៧ឆ្នាំ ដាក់ពន្ធនាគារកំណត់ ១ឆ្នាំ ៦ខែ (មួយឆ្នាំប្រាំមួយខែ) ពីបទ **លួចមានស្ថានទម្ងន់ទោស** ។

គ- ឈ្មោះ [redacted] ចាយ ហៅ ចៃ ភេទប្រុស អាយុ ៣៨ឆ្នាំ ដាក់ពន្ធនាគារកំណត់ ០៣ (បី) ឆ្នាំ ពីបទ **សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោស** ។

ប្រព្រឹត្តនៅភូមិ ១០ សង្កាត់បឹង សាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រម ព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។

២- សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី ០៩ ខែធ្នូ ឆ្នាំ២០១១ វេលាម៉ោង ២រសៀល និងប្រកាសជាសាធារណៈ នៅថ្ងៃទី ២១ ខែធ្នូ ឆ្នាំ២០១១ វេលាម៉ោង ២រសៀល ចំពោះមុខជនជាប់ចោទ និងកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី។

បើកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

- បានឃើញ សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ២០១១ របស់ឈ្មោះ [redacted] រ័ត្ន ជាជនជាប់ចោទ សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១៣៦ ក្រ.១ "ង" ចុះថ្ងៃទី ២១ ខែធ្នូ ឆ្នាំ២០១១ របស់សាលាដំបូង រាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

- បានឃើញ សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ០៣ ខែមករា ឆ្នាំ២០១២ របស់ឈ្មោះ [redacted] ចាយ ជាជនជាប់ចោទ សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១៣៦ ក្រ.១ "ង" ចុះថ្ងៃទី ២១ ខែធ្នូ ឆ្នាំ២០១១ របស់សាលាដំបូង រាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍។

- បានឃើញរបាយការណ៍រឿងព្រហ្មទណ្ឌរបស់ចៅក្រមរបាយការណ៍ សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍។

<u>នាពេលសវនាការ</u>

- ជនជាប់ចោទឈ្មោះ [redacted] រ័ត្ន . [redacted] ចាយ (វត្តមាន)

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សម្បត្តិ (អវត្តមាន)

- លោក [redacted] ចន្ថា ជាមេធាវីការពារជនជាប់ចោទ (វត្តមាន)

ជនជាប់ចោទឈ្មោះ [redacted] រ័ត្ន ឆ្លើយថាៈ ខ្លួនប្តឹងឧទ្ធរណ៍ដើម្បីសុំឱ្យតុលាការបន្ធូរបន្ថយទោស ខ្លួនដឹងកំហុស ហើយ ខ្លួនពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន ពេលធ្វើសកម្មភាពប្លន់មានគ្នាពីរនាក់។ ឈ្មោះ [redacted] ចាយ ពុំបាន ចូលរួមប្លន់ជាមួយខ្លួនទេ គឺគាត់គ្រាន់តែជាអ្នកយកម៉ូតូទៅលក់តែប៉ុណ្ណោះ។ ពេលធ្វើសកម្មភាពប្លន់ខ្លួនយកម៉ូតូបានមួយ គ្រឿងម៉ាក Step ពេលប្លន់បានទើបយកម៉ូតូទៅឱ្យឈ្មោះ [redacted] ចាយ យកទៅលក់។ សំណូមពរសុំឱ្យតុលាការមេត្តាបន្ធូរ បន្ថយទោសឱ្យខ្លួនផង។

ជនជាប់ចោទឈ្មោះ [redacted] ចាយ ឆ្លើយថាៈ ខ្លួនប្តឹងឧទ្ធរណ៍ដើម្បីសុំឱ្យតុលាការបន្ធូរបន្ថយទោស ខ្លួនពិតជាបាន ប្រព្រឹត្តដូចការចោទប្រកាន់មែន ខ្លួនសូមសារភាពនូវកំហុសរបស់ខ្លួន ខ្លួនជាអ្នកយកម៉ូតូទៅលក់បាន១៥០ដុល្លារ គេឱ្យ ខ្លួន២០ដុល្លារ ខ្លួនពុំបានចូលរួមប្លន់ជាមួយគេទេ ខ្លួនជាអ្នកយកម៉ូតូទៅលក់។ លក់ម៉ូតូលើកទី២ ឈ្មោះ [redacted] រ័ត្ន ឱ្យយក ម៉ូតូទៅលក់ គេឱ្យ៥០០ដុល្លារ តែឱ្យលុយ២៥០ដុល្លារ ឱ្យថ្លៃថ្នាំញៀន២៥០ដុល្លារ ហើយឈ្មោះ [redacted] រ័ត្ន មិនឱ្យលក់ក៏យក មកវិញ។ សំណូមពរសុំឱ្យតុលាការមេត្តាបន្ធូរបន្ថយទោសឱ្យខ្លួនផង។

តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ធ្វើសេចក្ដីសន្និដ្ឋានថាៈ សុំឱ្យក្រុមប្រឹក្សាតម្កល់សាលក្រមរបស់សាលាដំបូងទុកជាបានការ ដោយសុំឱ្យក្រុមប្រឹក្សាកែប្រែបទចោទប្រកាន់លើឈ្មោះ [redacted] ចាយ មកបទល្មើសទទួលផលចោរកម្មវិញ ។

លោក [redacted] ចន្ថា ជាមេធាវីការពារជនជាប់ចោទ ធ្វើសេចក្ដីថ្លែងហេតុថាៈ កូនក្ដីខ្លួនទាំងពីរនាក់បានសារភាពនូវកំហុសរបស់ខ្លួនដែលបានធ្វើទាំងពីរករណីយ៉ាងស្មោះពីចិត្តរបស់ខ្លួនអស់ហើយ ហើយប្ដឹងឧទ្ធរណ៍មកនេះក៏ដើម្បីសុំបន្ធូរបន្ថយទោសដល់ខ្លួន ចំពោះឈ្មោះ [redacted] ចាយ វិញគឺគ្រាន់តែជាអ្នកយកម៉ូតូទៅលក់តែប៉ុណ្ណោះ ។

- ក្រោយពីបានស្ដាប់ចម្លើយជនជាប់ចោទទាំងពីរនាក់ និងអំណានចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទទាំងពីរនាក់
- ក្រោយពីបានពិនិត្យពិភាក្សា និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ។

## សភាព្រហ្មទណ្ឌ យល់ឃើញថា

១-ពាក្យបណ្ដឹងឧទ្ធរណ៍លេខ ៩០៥ ចុះថ្ងៃទី២៨-១២-២០១១ របស់ជនជាប់ចោទឈ្មោះ [redacted] រ័ត្ន និងពាក្យបណ្ដឹងឧទ្ធរណ៍លេខ ០២ ចុះថ្ងៃទី០៣-០១-២០១២ របស់ជនជាប់ចោទឈ្មោះ [redacted] ចាយ ប្ដឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១៣៦ ក្រ.១"ង" ចុះថ្ងៃទី២១-១២-២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្ដីសម្រេច បានធ្វើឡើងត្រឹមត្រូវតាមកំណត់ច្បាប់ យោងតាមមាត្រា ៣៧៣ មាត្រា ៣៧៥ មាត្រា ៣៧៦ និងមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលអាចឱ្យសាលាឧទ្ធរណ៍ទទួលយកសំណុំរឿងព្រហ្មទណ្ឌលេខ ៣០៦ ចុះថ្ងៃទី២៥-០៣-២០១៣ របស់សាលាឧទ្ធរណ៍ មកធ្វើការជំនុំជម្រះបាន ។

២-នាពេលសវនាជនជាប់ចោទឈ្មោះ [redacted] រ័ត្ន បានឆ្លើយថា ការដែលខ្លួនប្ដឹងមកនេះ គឺដើម្បីសុំឱ្យសាលាឧទ្ធរណ៍បន្ធូរបន្ថយទោសដល់ខ្លួន ហើយជនជាប់ចោទឈ្មោះ [redacted] ចាយ បានឆ្លើយថា ខ្លួនដឹងថាម៉ូតូដែលឈ្មោះ [redacted] រ័ត្ន យកមកឱ្យខ្លួនជួយលក់ គឺជាម៉ូតូបានមកពីអំពើលួច ដូច្នេះសុំឱ្យសាលាឧទ្ធរណ៍ជួយបន្ធូរបន្ថយទោស ។

៣-អំពើជួយលក់ម៉ូតូដែលជាផលនៃបទល្មើសគឺជាបទល្មើសទទួលផលចោរកម្ម បទល្មើសមានចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ ។

៤-មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] ចាយ ពីបទ ទទួលផលចោរកម្ម ប្រព្រឹត្តនៅភូមិ១០ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី០៦-០៧-២០១១ បទល្មើសមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ ។

៥-សំអាងហេតុ និងសេចក្ដីសម្រេចក្នុងសាលក្រមព្រហ្មទណ្ឌលេខ ១៣៦ ក្រ.១"ង" ចុះថ្ងៃទី២១-១២-២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ មានមូលហេតុត្រឹមត្រូវ គប្បីសាលាឧទ្ធរណ៍ចេញសាលដីកាតម្កល់សាលក្រមនេះទុកជាបានការ លើកលែងតែបទចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] ចាយ ពីបទ សមគំនិតក្នុងអំពើលួចដោយមានស្ថាន

ទំងន់ទោស បទល្មើសមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ២៩ មាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ មកជាបទល្មើសទទួលផលចោរកម្ម បទល្មើសមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ ។

៦-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋាន សុំឱ្យក្រុមប្រឹក្សាតម្កល់សាលក្រមរបស់សាលាដំបូងទុកជាបានការ ដោយសុំឱ្យក្រុមប្រឹក្សាកែប្រែបទចោទប្រកាន់លើឈ្មោះ [redacted] ចាយ មកបទល្មើសទទួលផលចោរកម្មវិញ ។

៧-មេធាវីការពារជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា កូនក្តីខ្លួនសារភាពនូវទង្វើរបស់ខ្លួន និងមានគំនិតភ្ញាក់រលឹក សុំឱ្យបន្ធូរបន្ថយទោសដល់កូនក្តីខ្លួនឈ្មោះ [redacted] រ័ត្ន ហើយឈ្មោះ [redacted] ចាយ សុំឱ្យបន្ធូរបន្ថយទោស និងប្តូរបទចោទប្រកាន់មកទទួលជាបទល្មើស ទទួលផលចោរកម្ម ។

## ហេតុដូច្នេះ វិនិច្ឆ័យសេចក្តី

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍លេខ ៩០៥ ចុះថ្ងៃទី២៨-១២-២០១១ របស់ជនជាប់ចោទឈ្មោះ [redacted] រ័ត្ន ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២-ទទួលពាក្យបណ្តឹងឧទ្ធរណ៍លេខ ០២ ចុះថ្ងៃទី០៣-០១-២០១២ របស់ជនជាប់ចោទឈ្មោះ [redacted] ចាយ ទុកជាត្រឹមត្រូវតាមច្បាប់ ។

៣-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១៣៦ ក្រ.១"ង" ចុះថ្ងៃទី២១-១២-២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ លើកលែងតែបទល្មើសដែលផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] ចាយ ត្រូវកែប្រែពីបទ សមគំនិតក្នុងអំពើលួចដោយមានស្ថានទំងន់ទោស បទល្មើសមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ២៩ មាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ មកជាបទល្មើស ទទួលផលចោរកម្ម បទល្មើសមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ ។

៤-បន្តការឃុំខ្លួនជនជាប់ចោទទាំងពីររូបតាមច្បាប់ ។

សាលដីកានេះធ្វើការជំនុំជម្រះនៅថ្ងៃទី១៦-០៩-២០១៣ ចំពោះមុខជនជាប់ចោទ និងប្រកាសជាសាធារណៈនៅថ្ងៃទី០១-១០-២០១៣ ទុកសិទ្ធិឱ្យប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំងគ្រប់ថ្នាក់ គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះឱ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់៕**

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted], [redacted] | ហត្ថលេខា: [redacted] |

បានឃើញ
ប្រធានសាលាឧទ្ធរណ៍

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១៥
ក្រឡាបញ្ជី



៣៣០